# ការណែនាំរបៀបអានរបាយការណ៏ទិន្នន័យគម្រោងធ្វើឲ្យមានជោគជ័យដល់ការអប់រំនិងអាជីព

**A Guide to the Academic and Career Success Initiative Reports - KHMER**

គោលបំណងនៃរបាយការណ៏នេះគឺដើម្បីបង្ហាញនូវវិធានការណ៏ដែលក្រសួងអប់រំបានកំពុងអនុវត្តដើម្បីរៀបត្រៀមបំរុងសិស្សសម្រាប់ឧត្តមសិក្សានិងអាជីព។ របាយការណ៏ទាំងនេះស្ទង់មើលការលូតលាស់របស់ក្រសួងអប់រំតំបន់ឡុងប៊ីចនិងសាលារៀនទាំងឡាយនៅក្រសួងអប់រំ ឆ្ពោះទៅកាន់គោលដៅឆ្នាំ២០១៣នៃគម្រោងធ្វើឲ្យមានជោគជ័យដល់ការអប់រំនិងអាជីព។

របាយការណ៏នីមួយៗមាន២ផ្នែក គឺ:(1) *គោលដៅនៃគម្រោងប្រចាំក្រសួងអប់រំទាំងមូល* និង (2) *តារាងបង្ហាញពីការលូតលាស់។*




ACSI Progress Report K-8 -Khmer

## ផ្នែកទី 1 : គោលដៅនៃគម្រោងប្រចាំក្រសួងអប់រំទាំងមូល

ផ្នែកនេះមានបង្ហាញនូវរង្វាស់ដែលក្រសួងអប់រំតាមដានមើលដើម្បីបញ្ជាក់ថាសិស្សនឹងទទួលបានជោគជ័យបន្ទាប់ពីរៀនចប់សាលាវិទ្យាល័យ។ ក្នុងរង្វាស់នីមួយៗមានគោលដៅឆ្នាំ២០០៩មួយ ដែលបង្ហាញពីកំរិតនៃការលូតលាស់ដែលត្រូវធ្វើឲ្យបានក្នុងកំឡុងពេលមួយឆ្នាំ ហើយនិងគោលដៅឆ្នាំ២០០៣ ដែលជាគោលដៅខ្ពស់ជាងគេនៃគម្រោងនេះ។ គោលដៅទាំងអស់សម្រាប់ឆ្នាំ២០០៣ត្រូវបានបង្កើតឡើងដោយសិស្សានុសិស្ស មាតាបិតា គ្រូបង្រៀន អភិបាលសាលា និងសមាជិកសហគមន៏។

ឧទាហរណ៏

នៅក្នុងតារាងខាងស្តាំនេះ រង្វាស់ទីមួយគឺជាភាគរយនៃសិស្សថ្នាក់ទី៥ដែលបានទទួលពិន្ទុគ្រប់គ្រាន់ឬប្រសើរជាងក្នុងផ្នែកភាសាសិល្បឹអង់គ្លេស។ ក្នុងឆ្នាំ២០០៩ សាលាបឋមសិក្សានិងសាលាថ្នាក់មត្តេយ្យដល់ទី៨(K-8) ព្រមទាំងក្រសួងអប់រំជាទូទៅ ត្រូវបានរំពឹងថាធ្វើឲ្យបានដូចគោលដៅនៃ 52% (ជួរទីពីរ)។ ដល់ឆ្នាំ២០១៣ សាលារៀននិងក្រសួងអប់រំត្រូវរំពឹងថានឹងធ្វើឲ្យបាន 70% នៃគោលដៅ។

គោលដៅគម្រោងអប់រំប្រចាំក្រសួងអប់រំទាំងមូល

| រង្វាស់ | គោលដៅ ឆ្នាំ២០០៩ | គោលដៅ ឆ្នាំ២០១៣ |
|---|---|---|
| ភាពត្រៀមជាស្រេចសម្រាប់អនុវិទ្យាល័យ | | |
| ភាពចេះគ្រប់គ្រាន់ភាសាសិល្បឹអង់គ្លេសនៅថ្នាក់ទី៥ | 52% | 70% |
| ភាពចេះគ្រប់គ្រាន់គណិតសាស្ត្រនៅថ្នាក់ទី៥ | 62% | 70% |

## ផ្នែកទី 2 : តារាងរបាយការណ៍នៃការលូតលាស់




រង្វាស់នីមួយៗមានតារាងរបាយការណ៍មួយ។ ដូចមានបង្ហាញ"របៀបអានតារាងរបាយការណ៍"នៅផ្នែកខាងឆ្វេងនេះ តារាងនីមួយៗមានបន្ទះបី ដែលតំណាងទិន្នន័យលទ្ធផលអប់រំសម្រាប់បីឆ្នាំ។ បន្ទះចុងគេមានពណ៌ដើម្បីបង្ហាញថាតើគោលដៅប្រចាំឆ្នាំបានធ្វើដូចគោលដៅនោះដល់កំរិតណានៅក្នុងឆ្នាំ២០០៩(បន្ទះពណ៌ស)។

### ឧទាហរណ៍

នៅក្នុងតារាងខាងស្តាំនេះ រង្វាស់ពីរត្រូវបានបង្ហាញ (១)ភាគរយនៃសិស្សសាលាវិទ្យាល័យដែលបានចុះឈ្មោះក្នុងថ្នាក់កំរិតខ្ពស់ (AP) ហើយ(២)ភាគរយការប្រឡង AP ដែលសិស្សបានប្រឡងជាប់។ តារាងទីមួយមានបន្ទះពណ៌បៃតងដែលបង្ហាញគោលដៅឆ្នាំ២០០៩ត្រូវធ្វើបាន២៨%។ តារាងទីពីរមានបន្ទះពណ៌លឿងដែលបង្ហាញអត្រាប្រឡងជាប់៥១%នោះគឺតិចជាងគោលដៅ៥៣%ឆ្នាំ២០០៩។




### ការពន្យល់អំពីរង្វាស់

| រង្វាស់ | ពណ៌នា | អត្ថប្រយោជន៍ |
|---|---|---|
| ភាពចេះគ្រប់គ្រាន់ភាសាសិល្ប៍អង់គ្លេសថ្នាក់ទី៥ | ភាគរយនៃសិស្សថ្នាក់ទី៥ដែលបានទទួលពិន្ទុមានចំណេះគ្រប់គ្រាន់ឬប្រសើរជាង ក្នុងមុខវិជ្ជាភាសាសិល្ប៍។ | សិស្សដែលចាប់ផ្តើមថ្នាក់ទី៦គួរតែមានជំនាញជាគោល។ ដែលចាំបាច់សម្រាប់ពេលផ្ទេរចូលទៅរៀននៅសាលាមធ្យមសិក្សា។ |
| ភាពចេះគ្រប់គ្រាន់គណិតវិទ្យាថ្នាក់ទី៥ | ភាគរយនៃសិស្សថ្នាក់ទី៥ដែលបានទទួលពិន្ទុមានចំណេះគ្រប់គ្រាន់ឬប្រសើរជាង ក្នុងមុខវិជ្ជាគណិតវិទ្យា។ | |
| ភាពចេះគ្រប់គ្រាន់ភាសាសិល្ប៍អង់គ្លេសថ្នាក់ទី៨ | ភាគរយនៃសិស្សថ្នាក់ទី៨ដែលបានទទួលពិន្ទុមានចំណេះគ្រប់គ្រាន់ឬប្រសើរជាង ក្នុងមុខវិជ្ជាភាសាសិល្ប៍។ | សិស្សដែលចាប់ផ្តើមសាលាវិទ្យាល័យគួរតែមានជំនាញជាគោល។ដើម្បីការសិក្សាដែលកាន់តែពិបាកៗនិងសម្រាប់រៀបចំខ្លួនដើម្បីការសិក្សានៅសាកលវិទ្យាល័យនិងអាជីព។ |
| ភាពចេះគ្រប់គ្រាន់គណិតវិទ្យាទូទៅថ្នាក់ទី៨ | ភាគរយនៃសិស្សថ្នាក់ទី៨ដែលបានទទួលពិន្ទុមានចំណេះគ្រប់គ្រាន់ឬប្រសើរជាង ក្នុងមុខវិជ្ជាគណិតវិទ្យាទូទៅ។ | |
| ភាពចេះគ្រប់គ្រាន់ពេជគណិតទី១ថ្នាក់ទី៨ | ភាគរយនៃសិស្សថ្នាក់ទី៨ដែលបានទទួលពិន្ទុមានចំណេះគ្រប់គ្រាន់ឬប្រសើរជាង ក្នុងមុខវិជ្ជាពេជគណិតទី១។ | ថ្នាក់ពេជគណិតត្រូវបានចាត់ទុកថាជាថ្នាក់មួយសំខាន់ដែលនាំទៅដល់ជោគជ័យក្នុងការសិក្សានៅមហាឬសាកលវិទ្យាល័យ។ |
| សមាមាត្រដែលបានធ្វើតែស្តពេជគណិតទី១ថ្នាក់ទី៨ | ភាគរយនៃសិស្សថ្នាក់ទី៨ដែលបានយកថ្នាក់ពេជគណិតហើយដែលបានប្រឡងតែស្តពេជគណិតទី១។ | |
| អត្រាដែលបានចូលរួមក្នុងកម្មវិធី AVID | ភាគរយនៃសិស្សនៅសាលាមធ្យមសិក្សានិងវិទ្យាល័យដែលចុះឈ្មោះយកថ្នាក់កំរិតខ្ពស់ AVID ។ | កម្មវិធី (AVID) គឺជាកម្មវិធីមួយដែលបានទទួលស្គាល់ទូទាំងប្រទេសដែលជាកម្មវិធីរៀបចំសិស្សតាំងពីនៅសាលាមធ្យមសិក្សាទៅដើម្បីលើកទឹកចិត្តឲ្យខិតខំសិក្សានិងរៀបចំខ្លួនសម្រាប់ការសិក្សានៅមហាឬសាកលវិទ្យាល័យ។ |

| រង្វាស់ | ពណ៌នា | អត្ថប្រយោជន៍ |
|---|---|---|
| **អត្រាសិស្សថ្នាក់ទី១០ប្រឡងជាប់ CAHSEE អង់គ្លេស** | ភាគរយនៃសិស្សថ្នាក់ទី១០ដែលបានប្រឡងជាប់ផ្នែកភាសាសិល្បិ៍អង់គ្លេសនៃការប្រឡងយកសញ្ញាប័ត្រវិទ្យាល័យក្នុងរដ្ឋកាលីហ្វ័រនីញ៉ា (CAHSEE). | សិស្សត្រូវប្រឡងឲ្យជាប់ទាំងពីរផ្នែកនៃតែស្ត CAHSEE ទើបបាន ទទួលសញ្ញាប័ត្រវិទ្យាល័យ។ |
| **អត្រាសិស្សថ្នាក់ទី១០ប្រឡងជាប់ CAHSEE គណិត** | ភាគរយនៃសិស្សថ្នាក់ទី១០ដែលបានប្រឡងជាប់ផ្នែកគណិតវិទ្យានៃការប្រឡងយកសញ្ញាប័ត្រវិទ្យាល័យក្នុងរដ្ឋកាលីហ្វ័រនីញ៉ា (CAHSEE). | |
| **អត្រាសិស្សថ្នាក់ទី១២រៀនចប់សាលាវិទ្យាល័យ** | ភាគរយនៃសិស្សដែលបានរៀនចប់វិទ្យាល័យយោងទៅតាមទិន្នន័យសិស្សបានទទួលសញ្ញាប័ត្រនិងសិស្សដែលរៀនមិនចប់វិទ្យាល័យក្នុងកំឡុងរយៈពេល៤ឆ្នាំ។ | សញ្ញាប័ត្រវិទ្យាល័យគឺជាតម្រូវការជាគោលមួយសម្រាប់ការសុំចូលរៀននៅមហាឬសាកលវិទ្យាល័យនិងសម្រាប់សុំរកការងារធ្វើ។ |
| **អត្រាសិស្សបំពេញតម្រូវការជំពូកថ្នាក់ "A-G"** | ភាគរយនៃសិស្សរៀនចប់វិទ្យាល័យដែលរៀនចប់វិទ្យាល័យដោយបានទទួលពិន្ទុ "C" ឬប្រសើរជាង លើថ្នាក់ទាំងអស់ដែលតម្រូវពីសាកលវិទ្យាល័យ University of California (UC) និង California State University (CSU). | សិស្សត្រូវយកឲ្យគ្រប់នូវថ្នាក់ជំពូក "A-G" ដែលជាថ្នាក់តម្រូវឲ្យមានយ៉ាងតិចសម្រាប់សុំចូលទៅរៀននៅសាលាសាកលវិទ្យាល័យទាំងពីរក្នុងរដ្ឋកាលីហ្វ័រនីញ៉ា គឺ UC & CSU. |
| **សិស្សដែលទទួលឲ្យចូលសាលាមហាឬសាកលវិទ្យាល័យ** | ភាគរយនៃសិស្សរៀនចប់វិទ្យាល័យដែលទៅរៀនបន្តនៅសាលាមហាវិទ្យាល័យ(២ឆ្នាំ) ឬសាកលវិទ្យាល័យ(៤ឆ្នាំ)។ | ការរៀនចប់ពីសាកលវិទ្យាល័យបង្កើនសក្តានុពលសម្រាប់ធ្វើការបានប្រាក់ខែខ្ពស់និងឲ្យមានសុវត្ថិភាពហិរញ្ញិកផ្ទាល់ខ្លួន។ |
| **សិស្សដែលចុះឈ្មោះយកថ្នាក់កំរិតខ្ពស់ AP** | ភាគរយនៃសិស្សវិទ្យាល័យដែលបានយកថ្នាក់កំរិតខ្ពស់ (AP) យ៉ាងតិចមួយថ្នាក់។ | ថ្នាក់ AP ជួយរៀបបំរុងសិស្សសម្រាប់ការសិក្សាដែលកាន់តែពិបាកនៅឧត្តមសិក្សា ស្របពេលដែលអនុញ្ញាតឲ្យសិស្សបានទទួលក្រេឌិតថ្នាក់នៅមហាវិទ្យាល័យផងដែរ។ |
| **អត្រាប្រឡងជាប់ថ្នាក់កំរិតខ្ពស់ AP** | ភាគរយនៃលិទ្ធផលប្រឡងថ្នាក់កំរិតខ្ពស់ (AP) ដែលបានទទួលពិន្ទុលេខ៣ឬប្រសើរជាង។ | |
| **សមាមាត្រដែលបានប្រឡងតែស្ត SAT** | ភាគរយនៃសិស្សវិទ្យាល័យថ្នាក់ទី១២ដែលបានធ្វើតែស្ត SAT ផ្នែកឲ្យហេតុផល តាមធម្មតាប្រើសម្រាប់ការសុំចូលទៅរៀននៅសាកលវិទ្យាល័យ ពេលសិស្សកំពុងនៅរៀននៅសាលាវិទ្យាល័យ។ | ពិន្ទុតែស SAT គឺជាសមាសភាគដ៏សំខាន់មួយសម្រាប់ការគិតគូពិចារណាជ្រើសរើសសិស្សឲ្យចូលរៀននៅសាលាសាកលវិទ្យាល័យទាំងឡាយ។ |
| **សមាមាត្រដែលបានប្រឡងតែស្ត EAP អង់គ្លេស** | ភាគរយនៃសិស្សថ្នាក់ទី១១ដែលមានសិទ្ធិហើយបានធ្វើតែស្តភាសាសិល្បិ៍អង់គ្លេសនៃកម្មវិធី (EAP). | លិទ្ធផលនៃតែស្ត EAP បង្ហាញឲ្យដឹងថាតើសិស្សថ្នាក់ទី១១មានជំនាញដែលចាំបាច់សម្រាប់យកថ្នាក់កំរិតមហាវិទ្យាល័យក្នុងមុខវិជ្ជាភាសាសិល្បិ៍អង់គ្លេសនិងគណិតវិទ្យាដែរឬទេ។ បើសិនជាសិស្សពុំមានជំនាញរួចរាល់ស្រេចនៅឡើយទេ សិស្សនោះនឹងមានមួយឆ្នាំទៀតនៅថ្នាក់ទី១២ដើម្បីខិតខំរៀនបណ្តុះជំនាញណាដែលនៅទន់ខ្សោយ។ |
| **សមាមាត្រដែលបានប្រឡងតែស្ត EAP គណិត** | ភាគរយនៃសិស្សថ្នាក់ទី១១ដែលមានសិទ្ធិហើយបានធ្វើតែស្តគណិតវិទ្យានៃកម្មវិធី (EAP). | |
| **អត្រាអញ្ញតកម្មប្រឡងតែស្ត EAP អង់គ្លេស** | ភាគរយនៃសិស្សដែលមានសិទ្ធិហើយបានធ្វើតែស្តភាសាសិល្បិ៍អង់គ្លេសនៃកម្មវិធី (EAP) ហើយដែលបានបង្ហាញឲ្យឃើញថាពួកគេត្រៀមខ្លួនស្រេចសម្រាប់ការសិក្សានៅមហាឬសាកលវិទ្យាល័យ។ | |
| **អត្រាអញ្ញតកម្មប្រឡងតែស្ត EAP គណិត** | ភាគរយនៃសិស្សដែលមានសិទ្ធិហើយបានធ្វើតែស្តគណិតវិទ្យានៃកម្មវិធី (EAP) ហើយដែលបានបង្ហាញឲ្យឃើញថាពួកគេត្រៀមខ្លួនស្រេចសម្រាប់ការសិក្សានៅមហាឬនៅសាកលវិទ្យាល័យ។ | |